# មេរៀនទី ១៤៥៖ ព្រះព្យាបាលជម្ងឺឃ្លង់របស់ណាម៉ាន់

## ២ពង្សាវតាក្សត្រ ៥៖១-១៦

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/O4-HLVnFPd0

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/oQ3gc0FCkJg

**គោលបំណង៖ ព្រះចង់ឱ្យយើងចេះបន្ទាបខ្លួន។**

**ខគម្ពីរចងចាំ៖ យ៉ាកុប ៤៖១០** *"ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នាឡើង។"*

**ចំរៀង** ( *យូធូបលីង* )៖

១. មានទន្លេជីវិត https://youtu.be/AP6fwLxUqK0

២. ព្រះអង្គទ្រង់អស្ចារ្យ https://youtu.be/QXEVqO94wpg

៣. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ https://youtu.be/7WO74xMesGU

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត "ប្រណាំងគ្នាឆ្កឹះកងកៅស៊ូ"



សម្ភារៈដែលត្រូវការ៖ ចាន៨ កៅស៊ូកង៤០ ទឹក កៅអី៤ ជ្រនង់ប្រហិត

១. ចែកកុមារជា៤ក្រុម

២. ត្រៀមចាន៤ដែលមានដាក់ទឹកនិងកៅស៊ូ ១០នៅក្នុងនោះ ហើយចានទទេ៤។ ដាក់ចានដែលមានកៅស៊ូមួយ និងចានទទេមួយនៅលើកៅអីមួយ

៣. នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទី១ត្រូវរត់ទៅកាន់កៅអី ដោយប្រើ ដៃម្ខាង បិទភ្នែករបស់គេមួយចំហៀង។ ពួកគេត្រូវបន្តបិទភ្នែក មួយចំហៀង ហើយប្រើជ្រនង់ស្រង់កៅស៊ូចេញពីទឹកម្តងមួយដាក់ទៅក្នុងចានទទេ

៤. ក្រុមណាដែលអាចស្រង់កៅស៊ូអស់មុនក្រុមនោះជាអ្នកឈ្នះ។ អ្នកអាចបន្តលេងល្បែងនេះបានប្រសិនបើមានពេលគ្រប់គ្រាន់

៥. បន្ទាប់ពីលេងល្បែងនេះចង់សូមពន្យល់កុមារថា ពួកគេនឹងទទួលបានជ័យជំនះប្រសិនបើគេស្តាប់តាមការណែនាំរបស់គ្រូ។ ហើយយើងគឺត្រូវតែស្តាប់តាមការណែនាំរបស់ព្រះជានិច្ច។

### ៤. ការណែនាំមេរៀន

មានច្រើនដងដែលការអធិស្ឋានរបស់យើងមិនត្រូវបានឆ្លើយតប ឬក៏មានការអាក្រក់ណាមួយកើតឡើងចំពោះយើង។ ដែលពេលទាំងនោះធ្វើឱ្យយើងពិបាកក្នុងការជឿថាព្រះពិតជាស្រឡាញ់យើងមែន។ ប៉ុន្តែយើងត្រូវតែជឿជាក់លើទ្រង់ ពីព្រោះទ្រង់មិនដែលបោះបង់យើងនោះទេ! នៅថ្ងៃនេះ សូមឱ្យយើងបានរៀនពីបុរសម្នាក់ដែលបានរៀនពីមេរៀនសំខាន់មួយគឺជាការបន្ទាបខ្លួននៅចំពោះព្រះ!

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយមានក្មេងស្រីម្នាក់ដែលជាមនុស្សស្រឡាញ់ព្រះ ដែលត្រូវបានចាប់ខ្លួនដោយទាហានរបស់ស៊ីរីដែលជាខ្មាំងសត្រូវរបស់អ៊ីស្រាអែល។ នាងត្រូវបានគេចាប់យកចេញឆ្ងាយពីផ្ទះ និងក្រុមគ្រួសាររបស់នាង ហើយនាងបានក្លាយទៅជាអ្នកបម្រើម្នាក់។ ប៉ុន្តែនាងនៅតែទុកចិត្តព្រះ និងមានសេចក្តីជំនឿទៅលើ

អំណាចរបស់ព្រះ។

ចៅហ្វាយរបស់នាងគឺជាបុរសម្នាក់ដែលមានឈ្មោះថា ណាម៉ាន់ ដែលគាត់គឺជាមេទ័ពម្នាក់នៅក្នុងជួរកងទ័ពរបស់ស្តេច។ ប៉ុន្តែណាម៉ាន់មានបញ្ហាដ៏ធំមួយ គឺដោយព្រោះគាត់មានជម្ងឺឃ្លង់។ ឃ្លង់ជាជម្ងឺដ៏គួរឱ្យខ្លាចបំផុតនៅជំនាន់នោះ ពីព្រោះវាធ្វើឱ្យស្បែក និង ឆ្អឹងរលួយហើយអាចស្លាប់បាន។ ជាជម្ងឺដែលគ្មានថ្នាំព្យាបាល និង ងាយឆ្លងខ្លាំងផងដែរ។

ប៉ុន្តែក្មេងស្រីអ៊ីស្រាអែលម្នាក់នេះបានដឹងថាព្រះអាចព្យាបាលណាម៉ាន់បាន នាងបានប្រាប់គាត់ឱ្យទៅជួបហោរាម្នាក់ឈ្មោះអេលីសេ។ ដូច្នេះណាម៉ាន់ក៏បានទៅជួបជាមួយនឹងអេលីសេ។ អេលីសេមិនបានចេញមកស្វាគមន៍គាត់ទេ ប៉ុន្តែបានប្រាប់ទៅណាម៉ាន់ថា “ទៅមុជទឹកក្នុងទន្លេយ័រដាន់៧ដងទៅ នោះសាច់របស់លោកនឹងបានជា”

នៅពេលនោះ ណាម៉ាន់ខឹងយ៉ាងខ្លាំង។ គាត់បានរំពឹងថាលោកអេលីសេនឹងបង្ហាញការគោរពដល់គាត់ពីព្រោះគាត់ជាមេទ័ពដ៏អស្ចារ្យម្នាក់នៅក្នុងជួរកងទ័ពស្តេចស៊ីរី! ណាម៉ាន់មិនចង់ទៅមុជទឹក៧ ដងនៅក្នុងទន្លេយ័រដាន់នោះទេ ពីព្រោះនៅស៊ីរី មានទន្លេធំ និង ទឹកស្អាតជាងទន្លេយ័រដាន់ទៀតនោះ! ប៉ុន្តែអ្នកបម្រើរបស់គាត់បាននិយាយបញ្ចុះបញ្ចូលគាត់ឱ្យធ្វើតាមអ្វីដែលលោកអេលីសេបានបង្គាប់នោះ។

នៅពេលដែលណាម៉ាន់បានទៅមុជទឹកនៅក្នុង ទន្លេយ័រដាន់៧ដង គាត់ពិតជាបានជាសះស្បើយ ពីជម្ងឺឃ្លង់របស់គាត់មែន!នៅពេលដែលណាម៉ាន់បានបន្ទាបខ្លួនរបស់គាត់ដោយការស្តាប់បង្គាប់ហោរា ការអស្ចារ្យគឺពិតជាកើតឡើងចំពោះគាត់មែន! ព្រះអង្គល្អ ហើយគ្រប់យ៉ាងដែលទ្រង់ធ្វើគឺធ្វើដោយសេចក្តីស្រឡាញ់។ ព្រះមិនចង់ឱ្យណាម៉ាន់ដាក់សេចក្តីជំនឿទៅលើហោរាអេលីសេនោះទេ ប៉ុន្តែទ្រង់ចង់ឱ្យគាត់ជឿលើអំណាចរបស់ព្រះវិញ! គាត់អាចទទួលបាននូវបទពិសោធន៍ពីអំណាចរបស់ព្រះលុះត្រាតែគាត់បន្ទាបខ្លួននិងស្តាប់បង្គាប់ព្រះតែប៉ុណ្ណោះ។

ជួនកាល យើងគិតថាយើងមានអំណាចដើម្បីធ្វើគ្រប់ការទាំងអស់ដែលយើងចង់។ ឬពេលខ្លះយើងគិតថាអ្នកដ៏ទៃគួរតែប្រព្រឹត្តចំពោះយើងប្រសើរជាងព្រោះយើងមានអារម្មណ៍ថាយើងសំខាន់ជាងពួកគេ។ ប៉ុន្តែវាសំខាន់ណាស់ក្នុងការចងចាំថា យើងអាចទទួលបទពិសោធន៍ពីព្រះចេស្តានៃព្រះបាន លុះត្រាតែយើងបន្ទាបខ្លួននៅចំពោះព្រះ និងទុកចិត្តតែលើព្រះចេស្តារបស់ព្រះប៉ុណ្ណោះ!

## ៦. សំនួរពិភាក្សា

១. តើក្មេងស្រីដែលជាជនជាតិអ៊ីស្រាអែលបានក្លាយជាអ្នកបម្រើនៅផ្ទះណាម៉ាន់ដោយរបៀបណា?
*(នាងត្រូវបានទាហានស៊ីរីចាប់ខ្លួនមក)*
២. តើនាងបានគិតអ្វីនៅពេលដែលឃើញណាម៉ាន់មានការឈឺចាប់ដោយជម្ងឺឃ្លង់នោះ?
*(នាងដឹងថា ព្រះជាម្ចាស់អាចព្យាបាលគាត់បាន)*
៣. តើលោកអេលីសេបានប្រាប់ណាម៉ាន់ឱ្យធ្វើអ្វី? *(ឱ្យគាត់មុជទឹកទន្លេយ័រដាន់ចំនួន ៧ដង)*
៤. ហេតុអ្វីបានជាណាម៉ាន់ខឹង? *(ដោយព្រោះគាត់រំពឹងថាអេលីសេនឹងគោរពគាត់ជាជាងការដែលគាត់ប្រាប់ឱ្យណាម៉ាន់ធ្វើតាមទៅវិញ)*
៥. តើមានរឿងអ្វីកើតឡើងនៅពេលដែលណាម៉ាន់បន្ទាបខ្លួន ហើយមុជទឹកទន្លេយ័រដាន់ចំនួន ៧ដង?
*(គាត់បានជាសះស្បើយពីជម្ងឺឃ្លង់)*
៦. បន្ទាប់ពីបានសិក្សាពីរឿងនេះមក តើអ្នកគិតថាអ្វីដែលព្រះចង់បានពីយើងរាល់គ្នា?
*(ទ្រង់ចង់ឱ្យយើងចេះបន្ទាបខ្លួន និង ទុកចិត្តលើព្រះចេស្តារបស់ទ្រង់)*

## ៧. ល្បែងកំសាន្ត “ពស់ចឹក”



សម្ភារៈដែលត្រូវការ៖ ខ្សែប្រវែង ១៥០ សង់ទីម៉ែត្រ ដបទឹកសុទ្ធ

១. ឲ្យកុមារឈរជារង្វង់

២. គ្រូត្រូវឈរនៅចំកណ្តាលរង្វង់ដោយកាន់ខ្សែដែលមានចងដបទឹកនៅខាងចុង

៣. គ្រូនឹងដាក់ដបទឹកនៅលើដីហើយចាប់ផ្តើមគ្រវីទៅឆ្វេងទៅស្តាំ។ ប្រសិនបើ
ដបទឹកប៉ះជើងកុមារណាម្នាក់នោះ គេនឹងចាញ់ ល្បែងនេះ។ ប្រសិនបើកុមារអាចលោតផុតដោយមិនប៉ះជើងពួកគេ នោះគេអាចបន្តលេងបាន

៤. បន្តលេងល្បែងនេះរហូតនៅសល់តែកុមារ៣នាក់ហើយពួកគេជាអ្នកឈ្នះ ល្បែងនេះ

៥. បន្ទាប់ពីលេងល្បែងនេះចប់ សូមពន្យល់កុមារថា មានការជាច្រើននៅក្នុងលោកីយ៍នេះដែលធ្វើឲ្យយើងឈឺ ចាប់។ ប៉ុន្តែព្រះគឺតែងតែព្យាបាល និងជួយសង្គ្រោះពួកយើង។ ដូច្នេះយើងត្រូវតែចេះបន្ទាបខ្លួនចំពោះព្រះជានិច្ច។

## ៨. ខគម្ពីរចងចាំ

**យ៉ាកុប ៤៖១០** “ចូរបន្ទាបខ្លួននៅចំពោះព្រះអម្ចាស់ នោះទ្រង់នឹងដំកើងអ្នករាល់គ្នា ឡើង។”

**Craft: “Naaman Humbly Obeys God”**

Materials Needed: Printed craft sheet, crayons, scissors, glue, popsicle sticks (or straw)

1. Have the children color Naaman and Jordan River.



2. Cut out Naaman and Jordan River and glue a stick (or straw) behind Naaman.
3. Cut a line on the Jordan River so that you can put Naaman through.
4. Have the children put Naaman with leprosy into the River and say, “We need to be humble and trust God!”
5. After the seventh time, have the children change to Naaman who is cured and say, “God is powerful and he always helps us!”



## ៩. ហត្ថកម្ម “ណាម៉ាន់បន្ទាបខ្លួនស្តាប់បង្គាប់ព្រះ”

សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពក្រដាសកិច្ចការនៅទំព័រខាងក្រោម, កូល័រ, កន្ត្រៃ, កាវបិត, ដងឈើការ៉េម (ឬក៏ទុយោជ័រ)



១. ឱ្យកុមារផាត់ពណ៌រូបណាម៉ាន់ និង ទន្លេយ័រដាន់

២. កាត់រូបណាម៉ាន់ និង ទន្លេយ័រដាន់ ហើយបិតដងឈើការ៉េម (ឬទុយោ) នៅខាងក្រោយរូបណាម៉ាន់

៣. កាត់តាមបន្ទាត់នៅក្នុងរូបទន្លេយ័រដាន់ ដើម្បីអាចដាក់រូបណាម៉ាន់ចូលបាន



៤. ឱ្យកុមារដាក់រូបណាម៉ាន់ដែលមានជម្ងឺឃ្លង់ចូលទៅក្នុងទន្លេហើយនិយាយថា “យើងត្រូវតែបន្ទាបខ្លួន និងជឿព្រះអង្គ!”

៥. បន្ទាប់ពីដាក់រូបណាម៉ាន់ ៧ ដង ឱ្យកុមារផ្លាស់ប្តូររូបណាម៉ាន់ដែលបានជាពីជម្ងឺហើយនិយាយថា “ព្រះអង្គមានអំណាច ហើយទ្រង់តែងតែជួយយើង!”

## ១០. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវបានបង្រៀនថាយើងត្រូវធ្វើជាអ្នកបម្រើដ៏រាបទាបរបស់ព្រះ។ តាមរយៈទំនាក់ទំនងរបស់យើងជាមួយទ្រង់ យើងអាចបង្ហាញយ៉ាងច្បាស់ពីសេចក្តីស្រឡាញ់របស់ព្រះយេស៊ូវ។ តើការបន្ទាបខ្លួនមានសារៈសំខាន់យ៉ាងណាក្នុងតួនាទីជាគ្រូបង្រៀនម្នាក់? ការមានចិត្តរាបទាបគឺសំខាន់ណាស់ក្នុងការរស់នៅតាមសេចក្តីជំនឿរបស់យើង។ ប៉ុន្តែវាក៏ជាកត្តាចាំបាច់ផងដែរ ដែលយើងព្យាយាមសម្លឹងទៅកាន់ព្រះយេស៊ូវ ហើយបង្រៀនពីព្រះគុណរបស់ទ្រង់ដល់អ្នកដទៃ។ ចូរទូលសូមដល់ព្រះឱ្យទ្រង់បានបន្ទាប និង បង្រៀនអ្នកដើម្បីជួយបង្កើតនូវសេចក្តីជំនឿសម្រាប់កុមារ។

## “ណាម៉ាន់បន្ទាបខ្លួនស្តាប់បង្គាប់ព្រះ”





**Instruction:**



១.ឱ្យកុមារផាត់ពណ៌រូបណាម៉ាន់ និង ទន្លេយ័រដាន់

២. កាត់រូបណាម៉ាន់ និង ទន្លេយ័រដាន់ ហើយបិតដងឈើការ៉េម (ឬទុយោ) នៅខាងក្រោយរូបណាម៉ាន់

៣. កាត់តាមបន្ទាត់នៅក្នុងរូបទន្លេយ័រដាន់ ដើម្បីអាចដាក់រូបណាម៉ាន់ចូលបាន

៤. ឱ្យកុមារដាក់រូបណាម៉ាន់ដែលមានជម្ងឺឃ្លង់ចូលទៅក្នុងទន្លេហើយនិយាយថា “យើងត្រូវតែបន្ទាបខ្លួន និងជឿព្រះអង្គ!”



៥. បន្ទាប់ពីដាក់រូបណាម៉ាន់ ៧ ដង ឱ្យកុមារផ្លាស់ប្តូររូបណាម៉ាន់ដែលបានជាពីជម្ងឺហើយនិយាយថា “ព្រះអង្គមានអំណាច ហើយទ្រង់តែងតែជួយយើង!”